**អ្នកសារព័ត៌មានកម្ពុជាពីររូបឈ្នះរង្វាន់អ្នកនិពន្ធ**

**ក្រុមសិទ្ធិមនុស្សផ្តល់កត្តិយសដល់អ្នកការពារសារព័ត៌មានឯករាជ្យនៅកម្ពុជា**

*(ញូវយក ថ្ងៃទី២២ កក្កដា ២០០៨) អង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយនៅថ្ងៃនេះថា អ្នកសារព័ត៌មានវ័យក្មេងពីររូបគឺ ឈាង បុប្ផា និងដួង សុខា គឺជាអ្នកនិពន្ធសារព័ត៌មានពីររូបក្នុងចំណោមអ្នកនិពន្ធសារព័ត៌មាន ៣៤ រូបពីប្រទេសចំនួន ១៩ ទទួលបានរង្វាន់ប្រកបដោយកិត្យានុភាពរបស់អ្នកនិពន្ធហាំម៉េត/ហេលមែន ដែលទទួលស្គាល់នូវសេចក្តីក្លាហានក្នុងការប្រឈមមុខនឹងការធ្វើទុក្ខបុកម្នេញខាងនយោបាយ ។*

*រង្វាន់របស់អ្នកនិពន្ធហាំម៉េត/ហេលមែន ដែលគ្រប់គ្រងដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានប្រគល់ជូនជារៀងរាល់ឆ្នាំដល់អ្នកនិពន្ធនៅជុំវិញពិភពលោក ដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញខាងនយោបាយ ឬការរំលោភសិទ្ធិមនុស្ស។ កម្មវិធីប្រគល់រង្វាន់បានចាប់ផ្តើមក្នុងឆ្នាំ១៩៨៩ ជាពេលដែលអ្នកនិពន្ធជនជាតិអាមេរិកអ្នកនាងលីលាន ហេលមែន បានធ្វើបណ្តាំមរតកថា ភោគទ្រព្យរបស់នាងគួរដាក់ឲ្យប្រើប្រាស់ ដើម្បីជួយដល់អ្នកនិពន្ធទាំងឡាយដែលត្រូវការហិរញ្ញវត្ថុជាចាំបាច់អាស្រ័យដោយការសម្តែងទស្សនៈរបស់ពួកគេ។*

*អ្នកស្រីសារ៉ាខុម អ្នកស្រាវជ្រាវជាន់ខ្ពស់ប្រចាំអាស៊ីនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានមានប្រសាសន៍ថា ឈាង បុប្ផា និង ដួង សុខា តំណាងឲ្យចំនួនភាគតិចដ៏តូចមួយក្នុងចំណោមអង្គភាពសារព័ត៌មានរបស់ប្រទេសកម្ពុជា ដែលហ៊ាននិយាយប្រឆាំងស្ថាប័នពុករលួយ និងស្ថាប័នដែលមានភាពលំអៀងខាងនយោបាយតាមរយៈការនិពន្ធនិងសកម្មភាពរបស់ពួកគេ។*

*បុប្ផា អាយុ២៨ ឆ្នាំ និង សុខា អាយុ២៧ ឆ្នាំ បានធ្វើការជាអ្នករាយការណ៍ឲ្យសារព័ត៌មានកាំបូស្ទ័រ*

ដែលជាកាសែតប្រចាំថ្ងៃជាភាសាបារាំងនាំមុខគេនៅប្រទេសកម្ពុជា។ ពួកគេបានចាកចេញពីកាសែតនេះក្នុងឆ្នាំ២០០៧ ក្នុងការតវ៉ាប្រឆាំងនឹងការបណ្តេញចេញសហសេវិកម្នាក់ ដែលគេបណ្តេញចោលដោយសារតែការសរសេរអំពីរបាយការណ៍មួយរបស់អង្គការក្លូបលវីតណេស ដែលជាអង្គការបរិស្ថានអន្តរជាតិមួយ ដែលបានចងក្រងឯកសារទាក់ទងនឹងបទចោទសមគំនិតរបស់មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ក្នុងការរកស៊ីកាប់ឈើហ៊ុបខុសច្បាប់។

បុគ្គលិកខ្មែរបានជ្រើសរើស សុខា ជាអ្នកនាំពាក្យរបស់ពួកគេ ក្នុងការទាមទារឲ្យកាសែតកាំបូស្ស៊័រយកអ្នកសារព័ត៌មានដែលបណ្តេញចេញ ឲ្យមកកន្លែងដើមវិញ និងធានាដល់ឯករាជ្យភាពនៃការបោះពុម្ពផ្សាយ។ ម្ចាស់កាសែតបានឆ្លើយតបវិញដោយការបិទកាសែតនិងបើកវាឡើងវិញពីរបីខែក្រោយមកស្ថិតក្រោមការគ្រប់គ្រងបោះពុម្ពផ្សាយថ្មី។ ភាគច្រើននៃអតីតនិយោជិកបានត្រឡប់មកធ្វើការវិញជាយថាហេតុ ដោយគ្មានការធានាពីឯករាជ្យភាពនៃការបោះពុម្ពផ្សាយទេ ប៉ុន្តែ បុប្ផានិងសុខា បានច្រានចោលទោះជាមានការគាបសង្កត់ឲ្យធ្វើដូច្នេះក៏ដោយ។

ពួកគេទាំងពីរបានស្វែងរកការងារតិចដែលមានកម្រៃច្រើនក្នុងការបង្រៀនខាងសារព័ត៌មានមុនពេលដែលពួកគេ ចូលរួមកម្លាំងជាមួយអ្នកសារព័ត៌មានដទៃទៀតជាយថាហេតុ ដើម្បីចាប់ផ្តើមការបោះផ្សាយតាមអិនធឺណិតឯករាជ្យមួយជាភាសាខ្មែរនិងបារាំង (http://www.ka-set.info) ឈ្មោះកាសែត។ នៅពេលឆាប់ៗនេះ បុប្ផានឹងចាកចេញទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសារព័ត៌មាននៅមជ្ឈមណ្ឌលហ្វឹកហ្វឺនសម្រាប់វិជ្ជាជីវៈអ្នកសារព័ត៌មានក្នុងទីក្រុងប៉ារីស។

អ្នកស្រីសារ៉ាខុម បានមានប្រសាសន៍ថា "ក្នុងបរិយាកាសនៃការបង្ក្រាបសេរីភាពនៃការសម្តែងមតិនិងការវាយប្រហារប្រឆាំងនឹងសារព័ត៌មានឯករាជ្យ រាប់ទាំងការបង្ក្រាបនិងការវាយប្រហារពីកម្រិតខ្ពស់បំផុតរបស់រដ្ឋាភិបាលផង មានអ្នកសារព័ត៌មានតិចតួចហ៊ាននិយាយប្រឆាំងនឹងរបៀប

គ្រប់គ្រង។ សុខានិងបុប្ផា មានបំណងលើកកំពស់បទដ្ឋានវិជ្ជាជីវៈសារព័ត៌មាននៅក្នុងប្រទេសមួយដែលមានច្រកផ្សាយសារព័ត៌មានឯករាជ្យពិតៗដ៏តិចតួច។”

កាសែត ត្រូវបានបង្កើតឡើងដោយអតីតអ្នកសារព័តមាននិងអ្នកថតរូបឲ្យកាំបូស្ស័រចំនួនបួនរូប ក្នុងខែមីនា ឆ្នាំ២០០៨ ជាមួយនឹងប្រាក់ផ្ទាល់ខ្លួនរបស់អ្នកសារព័ត៌មាន។ វារាយការណ៍រឿងរ៉ាវមួយចំនួនធំ ដូចជានយោបាយ យុត្តិធម៌ សិទ្ធិមនុស្ស សេដ្ឋកិច្ច ខ្មែរក្រហម បរិស្ថាន វប្បធម៌ និងសង្គម។ ច្រកចូលទៅកាន់គេហទំព័រ (វិបសាយ) គឺឥតគិតថ្លៃ និងមានចំណូលពីការផ្សាយពាណិជ្ជកម្ម ទោះជាក្រុមមានចំនួនឡើងដល់ ១០ នាក់ហើយក្តី ក៏ក្រុមនេះកំពុងតែស្វែងរកជំនួយគាំទ្របន្ថែមនៅពេលបច្ចុប្បន្ននេះ។

អ្នកស្រីសារ៉ាខុម បានមានប្រសាសន៍ថា “ជំនាញវិជ្ជាជីវៈ ចរិយាមារយាទ និងសេចក្តីក្លាហានដ៏កម្ររកបាន ដែលតាំងបង្ហាញដោយដួង សុខា និងឈាង បុប្ផា គួរតែនាំគ្នាទះដៃអបអរសាទរ និងលើកទឹកចិត្ត ជាពិសេសនៅពេលដែលសារព័ត៌មានឯករាជ្យក្នុងប្រទេសកម្ពុជាកំពុងស្ថិតក្នុងកំណើនគ្រោះថ្នាក់។”

រដ្ឋាភិបាលកម្ពុជា ត្រួតត្រាគ្រឿងផ្សាយព័ត៌មានទាំងអស់ និងជាទៀងទាត់បញ្ឈប់បណ្តោះអាសន្ន គំរាមកំហែង ឬចាត់វិធានការណ៍ខាងផ្លូវច្បាប់ប្រឆាំងនឹងអ្នកសារព័ត៌មាន ឬច្រកផ្សាយព័ត៌មានដែលរិះគន់រដ្ឋាភិបាល។ បន្ថែមលើនេះទៀត អ្នកសារព័ត៌មានប្រឈមនឹងការបណ្តេញចេញ ការវាយប្រហារលើរូបរាងកាយ ឬមរណភាពដោយការនិយាយលើរឿងរ៉ាវទ។ ឧទាហរណ៍ នៅពេលថ្មីៗក្នុងខែនេះ បុរសប្រដាប់អាវុធបានបាញ់សម្លាប់លោកឃឹម សម្បូរណ៍ អ្នកសារព័ត៌មានឲ្យកាសែតប្រឆាំងឈ្មោះមនសិកាខ្មែរ។

អ្នកស្រីសារ៉ាខុម បានមានប្រសាសន៍ថា "ព្រោះតែការបង្រួមអំណាចខាងនយោបាយកើនឡើងក្នុងប្រទេសកម្ពុជាក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតជាតិនៅថ្ងៃទី២៧ ខែកក្កដា ដូច្នេះសារព័ត៌មានទទួលរងនូវការត្រួតត្រា។"

ក្នុងខែមិថុនា កងរាជអាវុធហត្ថបានចាប់លោកដាំសិទ្ធ និពន្ធនាយកមនសិកាខ្មែរ ដែលឈរឈ្មោះជាបេក្ខជនរបស់គណបក្សសមរង្ស៊ីក្នុងការបោះឆ្នោត បន្ទាប់ពីកាសែតរបស់លោករាយការណ៍ស្តីពីការចោទប្រកាន់លើតួនាទីរបស់រដ្ឋមន្ត្រីការបរទេសបច្ចុប្បន្នអំឡុងរបបខ្មែរក្រហម។

ក្នុងឆ្នាំ២០០៧ អ្នកសារព័ត៌មានមួយរូបក្នុងខេត្តពោធិសាត់ គឺជាជនរងគ្រោះនៃការវាយប្រហារបំណងដុតផ្ទះចំនួនពីរលើក ដែលប្រធាននគរបាលមូលដ្ឋានបានសន្មត់លើការផ្សាយអំពីការកាប់ឈើហ៊ុបខុសច្បាប់របស់អ្នកសារព័ត៌មានរូបនេះ។ អ្នកសារព័ត៌មានដែលផ្សាយសេចក្តីរាយការណ៍មួយ និងប្រជាពលរដ្ឋដែលជួយរៀបចំរបាយការណ៍ បានទទួលនូវការគំរាមសម្លាប់ពីជនអនាមិក។

បុប្ផាមានបរិញ្ញាប័ត្រផ្នែកអក្សរសាស្ត្របារាំងពីសកលវិទ្យាល័យភ្នំពេញ និងបរិញ្ញាប័ត្រផ្នែកគ្រប់គ្រងពីសកលវិទ្យាល័យជាតិគ្រប់គ្រង។ ធ្វើការឲ្យកាំបូស៊ូរ នាងរាយការណ៍អំពីការវាយប្រហារលើសិទ្ធិមនុស្ស ចងក្រងឯកសារយ៉ាងច្បាស់លាស់អំពីស្ថានភាពជនរងគ្រោះក្នុងរបបខ្មែរក្រហម ស្ថានភាពកម្មករកាត់ដេរ ស្ត្រី ជនជាតិភាគតិច និងកុមារ។ នាងបានធ្វើការជាអ្នកឆ្លើយឆ្លងព័ត៌មានឲ្យវិទ្យុបារាំងអន្តរជាតិ វិទ្យុអាស៊ីសេរី និងសេវាកម្មសារព័ត៌មានអន្តរជាតិ។ ក្នុងឆ្នាំ២០០៣ នាងជួយក្នុងការផលិតភាពយន្តឯកសារមួយឈ្មោះ "Les Artistes du Theatre Brulé" របស់លោករិទ្ធីប៉ាន់ អ្នកផលិតខ្សែភាពយន្តជនជាតិខ្មែរម្នាក់។ ផងដែរ បុប្ផាបានបង្រៀនវិជ្ជាជីវៈសារព័ត៌មានខាងការបោះពុម្ពផ្សាយនៅឯសកលវិទ្យាល័យភ្នំពេញ។

*សុខា សិក្សាភាសាបារាំងនៅសកលវិទ្យាល័យភ្នំពេញ។ ក្នុងអំឡុងរយៈពេលបួនឆ្នាំរបស់គាត់ជាមួយកាសែតកាំបូស៊ូរ សុខារាយការណ៍អំពីតុលាការ សិទ្ធិមនុស្ស និងនយោបាយ។ បន្ថែមលើនេះទៀត លោកធ្វើការជាអ្នកបង្រៀនភាសាបារាំងនៅសកលវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច ជាអ្នកគាំទ្រព្រឹត្តិការណ៍មួយឲ្យមជ្ឈមណ្ឌលធនធានសោតទស្សន៍បូបញ្ញា និងជាអ្នករាយការណ៍ទូរទស្សន៍ក្នុងកម្មវិធី "សម្លេងកម្ពុជា" ចាក់ផ្សាយតាមទូរទស្សន៍ប៉ុស្តិ៍លេខ៩ ក្នុងប្រទេសកម្ពុជា។*

*អ្នកស្រីសារ៉ាខុម បានមានប្រសាសន៍ថា "ថ្វីបើនៅវ័យក្មេង បុប្ផានិងសុខា បានទទួលនូវសេចក្តីគោរពចំពោះភាពជាអ្នកដឹកនាំនិងសេចក្តីសុចរិតរបស់ពួកគេ អំឡុងនិងបន្ទាប់ពីក្ដូដកម្មសារព័ត៌មាន និងការចុះផ្សាយរាយលុកយ៉ាងខ្លាំងក្លារបស់ពួកគេអំពីបញ្ហាសង្គមនិងសិទ្ធិមនុស្ស។"*

*ចាប់តាំងពីឆ្នាំ១៩៨៩ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានគ្រប់គ្រងរង្វាន់ហេលមែន/ហាំម៉េត ដែលបានផ្តល់ឲ្យដល់អ្នកនិពន្ធជិត ៧០០ នាក់រួចមកហើយ រួមទាំងអ្នកនិពន្ធកម្ពុជា ១០ នាក់ផងដែរក្នុងអំឡុងពេល ១៩ ឆ្នាំនៃកម្មវិធី។ កម្មវិធីហេលមែន/ហាំម៉េតក៏ផ្តល់មូលនិធិបន្ទាន់ខ្នាតតូចដល់អ្នកនិពន្ធទាំងឡាយដែលមានតម្រូវការចាកចេញពីប្រទេសជាបន្ទាន់ឬដែលត្រូវការការព្យាបាលផ្នែកពេទ្យជាបន្ទាន់បន្ទាប់ពីរយៈពេលនៃការជាប់ពន្ធនាគារ ឬទទួលរងនូវអំពើទារុណកម្ម។*

## សង្ខេបផ្ទៃរឿងសំខាន់របស់ឈាង បុប្ផា

*"ទោះជាយើងមិនអាចរិះគន់រដ្ឋាភិបាលដោយត្រង់ៗក៏ដោយ ក៏យើងត្រូវតែមានអារម្មណ៍ដោយសេរីក្នុងការនិពន្ធ។ យើងអាចបើកបង្ហាញរឿងរ៉ាវដែលអ្នកដទៃមិនអាច ... ទៅតាមវិជ្ជាជីវៈ។"*

*— ឈាង បុប្ផា*

*ឈាង បុប្ផានិយាយថានាងមិនមែនជាអ្នកសារព័ត៌មានល្អម្នាក់នោះទេ ពីព្រោះនាងផ្តោតការយកចិត្តទុកដាក់ច្រើនលើពាក្យពេចន៍ អារម្មណ៍ និងទស្សនៈនៃអំពើសង្កត់សង្កិន។ នាងនិយាយអំពីរឿងរ៉ាវរបស់នាងស្តីពីកម្មករកាត់ដេរ ជនរងគ្រោះក្នុងរបបខ្មែរក្រហម ជនជាតិភាគតិច និងកុមារថា "ខ្ញុំត្រូវការពារជនរងគ្រោះ" ។*

*អ្នកធ្វើការផ្នែកសិទ្ធិអបអរសាទរដល់ឥទ្ធិពលនៃរបាយការណ៍របស់នាង ដោយកត់សំគាល់ពីមជ្ឈដ្ឋានជាតុដ៏មាំមួនក្លាហានរបស់នាងអំពីស្ថាប័នទាំងអស់ រួមទាំងសេចក្តីរាយការណ៍ជាភាសាបារាំងខ្មែររបស់បុប្ផា ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវទស្សនៈរិះគន់និងប្លែកៗស្តីពីប្រទេសរបស់នាង។ បុប្ផា អាយុ២៨ ឆ្នាំ ធ្វើឲ្យរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលមានការទទួលខុសត្រូវ តាមការសម្ភាសន៍អំពីប្រធានបទរបស់នាងដែលអ្នកធ្វើការខាងសិទ្ធិ ពិពណ៌នាថា "មានលក្ខណៈប្រណាំងប្រជែង ត្រង់ចំៗ និងមានក្រមសីលធម៌ "។ ក្រៅពីវិធីដែលអាចធ្វើឲ្យភ្ញាក់ផ្អើលដល់អាជ្ញាធរមូលដ្ឋាន ស្ត្រី និងបុរសវ័យចាស់នាងនៅមានភាពទេពកោសល្យទំនាក់ទំនងនិង ជជែកសន្ទនាជាមួយមនុស្សគ្រប់ប្រភេទផ្សេងគ្នា។*

*បុប្ផាសន្មត់បទពិសោធន៍និងប្រាជ្ញាដ៏មានតម្លៃបំផុតរបស់នាងបានមកពីអ្នកទូន្មានពីររូប។ នាងហាត់ធ្វើការរយៈពេល ៦ ខែជាមួយរិទ្ធី ប៉ាន់ ដែលជាអ្នកផលិតខ្សែភាពយន្តកម្ពុជា ដែលនាងពិពណ៌នាថាជា "អ្នកក្លាហានមួយរូប" ដែលបើកបង្ហាញបញ្ហាអាថ៌កំបាំងនិងដ៏ស្រៀវស្រើបរបស់សង្គម។*

អ្នកទូន្មានទីពីរគឺសហសេវិកសារព័ត៌មានជនជាតិបារាំង ដែលជម្រុញឲ្យនាងជជីកកកាយបង្កើបព័ត៌មាននិងសួរសំណួរពិបាកៗដោយមិនចាំបាច់មានបុរេនិច្ច័យ។

បុប្ផានិយាយបន្ថែមទៀតថា រូបមន្តនេះជាគ្រឿងផ្សំចាំបាច់មួយដែលមានការខ្វះខាតនៅក្នុងវិជ្ជាជីវៈសារព័ត៌មានកម្ពុជា: នាងនិយាយថា ពេលវេលា "ត្រូវផ្តល់ពេលដល់ប្រជាពលរដ្ឋ។ អនុញ្ញាតឲ្យពួកគេបានគិត"។ នាងបង្រៀនខ្លួនឯងឲ្យចេះធ្វើការងារជាមួយមនុស្សគ្រប់ប្រភេទទាំងអស់ ដោយពន្យល់ថា "អាក្រក់, ចរចេស" ប្រជាពលរដ្ឋជាធម្មតាឆាប់ងាយរងគ្រោះណាស់ និងជួនកាលងាយបែកបាក់។

នាងបង្កើតអាជីពខាងសារព័ត៌មានរបស់នាងជាមួយកាំបូស្ជ័រ ជាកាសែតភាសាបារាំងខ្មែរ (ក្រោយមក នាងរាយការណ៍ឲ្យវិទ្យុបារាំងអន្តរជាតិ) ដែលជាកន្លែងដែលគេផ្តល់ឱកាសឲ្យនាងស្វែងរករឿងដោយផ្ទាល់ខ្លួនឯង។ ការរាយការណ៍អំពីរឿងរ៉ាវរបស់ស្ត្រីនៅតាមខេត្តគឺជាសេចក្តីខ្វល់ខ្វាយដំបូងរបស់នាង។

ដើមដំបូង សហសេវិករបស់នាងរិះគន់នាងអំពីប្រការដែលនាងមិនព្រមស្លៀកសំពត់និងអាកប្បកិរិយារបស់នាងដែលពួកគេយល់ថាមិនសមរម្យតាមប្រពៃណីជាស្ត្រីកម្ពុជា។ នាងនិយាយថា "ពួកគេនិយាយឲ្យនាងថា អ្នកគួរតែធ្វើការនៅឯផ្ទះ ចំអិនអាហារឲ្យប្តី ឬឪពុកម្តាយ" ។ នាងនិយាយបន្ថែមទៀតថា "គេមិនដែលយល់អំពីស្ត្រីទេ" ។ ដោយមិនឲ្យគេផ្ចាញ់ផ្ចាលនាង នាងបានចាត់ចែងផ្លាស់ប្តូរមតិរបស់ពួកគេ "បន្តិចបន្តួច" នៅពេលនាងធ្វើដំណើរចុះទៅតាមខេត្ត ជាទីដែលនាងនិយាយថាមានរឿងរ៉ាវគួរឲ្យចាប់

អារម្មណ៍ជាច្រើននៅទីនោះ និងជាកិច្ចការមួយដែលអ្នកដទៃបានជៀសវាងអាស្រ័យតាមកាតព្វកិច្ចគ្រួសារ ការដាក់កំហិតពេលវេលានិងហិរញ្ញវត្ថុ ។

នាងចាប់មានកេរ្តិ៍ឈ្មោះយ៉ាងឆាប់រហ័សពីព្រោះតែការធ្វើជា "ជាអ្នកនិយមលើកតម្កើងឋានៈរបស់ស្ត្រី" និងតាមការរាយការណ៍អំពីស្ថានភាពរបស់អ្នករងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនិងការជួញដូរ ស្ថានភាពអ្នកធ្វើការបម្រើផ្លូវភេទ និងកម្មករកាត់ដេររោងចក្រ។ នាងនិយាយថា " ខ្ញុំការពារស្ត្រីដែលធ្វើការរួមគ្នាប្រយុទ្ធប្រឆាំងអំពើអយុត្តិធម៌។"

បុប្ផាសារភាពថា ការងាររបស់នាងជួនកាលប្រកបដោយគ្រោះថ្នាក់ ដូចជាការចុះទៅតំបន់ដ៏រឹងមាំរបស់ខ្មែរក្រហមនៅប៉ៃលិននិងម៉ាឡៃ ឬសម្ភាសន៍ជនរងគ្រោះដោយអយុត្តិធម៌សង្គម។ ក្នុងរឿងរបស់នាងស្តីអំពីសាលាក្តីខ្មែរក្រហម នាងពុះពារស្វែងរកការពិតដោយមិនដាក់ឲ្យជនរងគ្រោះទទួលរងនូវស្លាកស្នាមឈឺចាប់សារជាថ្មីទៀតឡើយ។

បុប្ផាជាមនុស្សមានការវិភាគ ចេះគិតគូរ និងមានគោលការណ៍ចំពោះព្រឹត្តិការណ៍ដែលនាំទៅរកការបិទកាំបូស្ជ័រ និងការចាកចេញរបស់នាងពីកាសែតក្នុងឆ្នាំ២០០៧។ នាងនិយាយថា " អ្នកគ្រប់គ្រងប្រើប្រាស់អ្នកសារព័ត៌មានឲ្យវាយប្រហារគ្នាទៅវិញទៅមក" បំផ្លិចបំផ្លាញចំណងសហសេវិក បង្ខិតបង្ខំឲ្យក្រុមអ្នកនិពន្ធជាតិបារាំងភាគច្រើនចាកចេញ និងបញ្ឆោតអ្នកនិពន្ធកម្ពុជា។

*នាងនិយាយថា "ទោះជាយើងមិនអាចរិះគន់រដ្ឋាភិបាលដោយត្រង់ៗក៏ដោយ ក៏យើងត្រូវតែមានអារម្មណ៍ដោយសេរីក្នុងការនិពន្ធរឿងខ្លះ។ ជាអ្នកសារព័ត៌មាន យើងអាចបើកបង្ហាញរឿងរ៉ាវដែលអ្នកដទៃមិនអាច។"*

*នាងមិនព្រមសម្រុះសម្រួលចរិយាមារយាទនិងឯករាជ្យភាពរបស់នាងដើម្បីបានគ្រឿងលើកទឹកចិត្តជាហិរញ្ញវត្ថុឡើយ។ នាងនិយាយថា សារព័ត៌មានជាច្រើនប្រតិបត្តិការដើម្បីផលប្រយោជន៍អ្នកមាន ឬអ្នកមានអំណាច។ បុប្ផាដឹងថាអតីតសហសេវិកខ្លះរបស់នាងកំពុងគិតអំពីគ្រួសារនិងសន្តិសុខ នៅពេលដែលពួកគេត្រូវបានគេលួងលោមឲ្យត្រឡប់ទៅកាន់សារព័ត៌មានវិញជាមួយនឹងប្រាក់ខែខ្ពស់។ សម្រាប់បុប្ផាវិញ ទោះជាយ៉ាងណាក៏ដោយ សារព័ត៌មានដែលមានវិជ្ជាជីវៈត្រូវតែក្លាហានឲ្យបានច្រើនជាងនេះ។*

## សង្ខេបផ្ទៃរឿងសំខាន់របស់ដួង សុខា

*"យើងចង់ការពារសារព័ត៌មានឯករាជ្យ។"*

*— ដួង សុខា ពន្យល់អំពីហេតុផលដែលគាត់ដឹកនាំបុគ្គលិកនិពន្ធរបស់កាប្ញូស្ទ័រ។*

*និយាយដោយថ្នមៗ ដួងសុខា មើលទៅហាក់មិនទំនងដូចជាអ្នកដើងឯកខាងសេរីភាពសម្តែងមតិទេ។ ជាមួយនឹងគតិបណ្ឌិតក្នុងវ័យលើស ២៦ ឆ្នាំរបស់គាត់ លោកសុខានិយាយថាសារព័ត៌មានឯករាជ្យគឺជាឧត្តមភាពមួយដែលអ្នកសារព័ត៌មានទាំងឡាយ ត្រូវតែតស៊ូពុះពារ និងទាមទារវាមកឲ្យបាន។*

*សុខានិយាយថា " ប្រសិនបើនិយាយអំពីសេរីភាពនៃសារព័ត៌មាន គ្រប់ព័ត៌មានទាំងអស់មានសិទ្ធិសរសេរនូវអ្វីដែលពួកគេចង់សរសេរ។" សុខានិយាយបន្ថែមទៀតថា សារព័ត៌មានទទួល*

ខុសត្រូវចំពោះការធ្វើសេចក្ដីរាយការណ៍ប្រកបដោយវិជ្ជាជីវៈ និងប្រកបដោយក្រមសីលធម៌។ សុខាដឹងច្បាស់ថា ការប្រើប្រាស់សិទ្ធិនោះ អាចទទួលរងគ្រោះថ្នាក់នៅក្នុងប្រទេសកម្ពុជា។

សុខា ការពារការចុះផ្សាយក្នុងខែមិថុនា ២០០៧ របស់កាំបូស្ទ័រនូវរបាយការណ៍ដ៏ស្រើបស្រាល ដែលបញ្ចេញឈ្មោះមន្ត្រីជាន់ខ្ពស់ដែលជាប់ពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់។ ដោយការដាក់ខ្លួនបន្ទាបរាបសារចំពោះតួនាទី គាត់បានដើរតួប្រកួតប្រឆាំងនឹងអ្នកគ្រប់គ្រងកាសែត។ គាត់និយាយថា ហេតុផលដែលសហសេវិករបស់គាត់ជ្រើសរើសគាត់ជាអ្នកនាំពាក្យគឺនៅត្រង់ថា "ខ្ញុំធ្វើនូវអ្វីដែលខ្ញុំនិយាយ។"

គាត់បានសម្រេចចិត្តរៀនវិជ្ជាជីវៈខាងសារព័ត៌មាននៅសកលវិទ្យាល័យភ្នំពេញក្នុងឆ្នាំ១៩៩៩ ដើម្បីផ្ដល់គំនិតនិងព័ត៌មានដល់ប្រជាពលរដ្ឋកម្ពុជាដើម្បីរៀនសូត្រអំពីសេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌។

ក្នុងរយៈពេលបួនឆ្នាំរបស់គាត់នៅឯកាសែតកាំបូស្ទ័រ លោកសុខាបានរាយការណ៍ទាក់ទងនឹងតុលាការ សិទ្ធិមនុស្ស និងនយោបាយ។ គាត់មានទេព្យកោសល្យនិងទំនុកចិត្តដើម្បីរាយការណ៍អំពីរឿងរ៉ាវខ្លះដែលអ្នករាយការណ៍ជនកម្ពុជាជៀសវាង រួមទាំងសាវនាកាដែលស្មុគ្រស្មាញ និងសហជីពកម្មករ។ គាត់គាំទ្រអត្ថបទសារព័ត៌មានរបស់គាត់ជាមួយនឹងកស្តុតាងពីការស៊ើបអង្កេត និងរក្សាវិជ្ជាជីវៈឲ្យនៅឃ្លាតឆ្ងាយពីអង្គការនិងមិត្តភក្តិ។

ដោយស្គាល់ពីភាពស្មោះត្រង់ ឯករាជ្យ និងមិនពុករលួយ  សហសេវិករបស់សុខាបានដឹងថា សុខាជាមនុស្សមានគោលការណ៍ ក្នុងការចរចារជាមួយអ្នកគ្រប់គ្រងកាំបូស្ទ័រក្នុងខែមិថុនា ឆ្នាំ២០០៧។ បន្ទាប់ពីអ្នកគ្រប់គ្រងមិនព្រមធានាឯករាជ្យភាពរបស់កាសែត  សុខាគឺជាអ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានពីរនាក់ដែលមិនព្រមត្រឡប់មកវិញ។

គាត់ចាប់ផ្តើមបង្រៀនវិជ្ជាជីវៈសារព័ត៌មាននៅសកលវិទ្យាល័យភ្នំពេញ ពីព្រោះគាត់ចង់លើកទឹកចិត្តដល់អ្នកជំនាន់ក្រោយឲ្យជ្រើសរើសជាអ្នកសារព័ត៌មានឯករាជ្យ។ ក្រោយមក គាត់ចាប់ផ្តើមគំនិតមួយជាមួយអតីតសហសេវិកមួយចំនួន ដើម្បីចាប់ផ្តើមសារព័ត៌មានថ្មីតាមអ៊ិនធឺណិតដែលមានឯករាជ្យ ផ្សាយជាភាសាខ្មែរនិងបារាំង ឈ្មោះថាកាសែត ។

ដំបូន្មានរបស់លោកដើម្បីលើកកំពស់សារព័ត៌មានកម្ពុជាឲ្យកាន់តែប្រសើរឡើងគឺថា " សារព័ត៌មានត្រូវតែមានឯករាជ្យភាព  ត្រូវស្ទួរប្រកពឲ្យបានច្រើន គោរពក្រមសីលធម៌ មិនប្រឌិតព័ត៌មាន ស្វែងរកការផ្សាយពាណិជ្ជកម្មឲ្យបានច្រើន និងឈប់សុំការគាំទ្រពីរដ្ឋាភិបាលនិងអ្នកមានទ្រព្យធន ហើយត្រូវផ្តល់ប្រាក់បៀវត្សដល់អ្នកសារព័ត៌មាន។

ជាអ្នកបោះពុម្ពផ្សាយរបស់កាសែត លោកសុខាសារភាពថា គាត់នៅមានកិច្ចការជាច្រើនដែលត្រូវរៀនសូត្រទាក់ទងនឹងការនិពន្ធនិងការគ្រប់គ្រងកាសែត។ គាត់និយាយថា ការប្រគួតប្រជែងជាបន្ទាន់បំផុតរបស់លោកក្នុងគ្រប់គ្រងសារព័ត៌មានឯករាជ្យមួយគឺហិរញ្ញវត្ថុ។ សុខានិយាយថា គាត់មានទំនុកចិត្តក្នុងការជួបនូវការប្រកួតប្រជែងបែបនោះ។

សុខាមានទស្សនៈវិស័យមួយអំពីសារព័ត៌មានកម្ពុជា ដែលប្រាប់ប្រជាពលរដ្ឋនិងលើកទឹកចិត្តពួកគេទ្រចូលរួមអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួន។ គាត់និយាយថា " ប្រសិនបើសារព័ត៌មានទាំងអស់ឯករាជ្យ  មន្ត្រីរដ្ឋាភិបាលនឹងមិនធ្វើនូវអ្វីដែលពួកគេចង់ធ្វើទេ។ អ្នកសារព័ត៌មានអាចបរិហារអំពើពុករលួយ និងបញ្ហាដទៃទៀតនៅក្នុងប្រទេស។ យើងនឹងឃើញ។ "

----//----